# សេចក្ដីជូនដំណឹង

ការិយាល័យសិក្សា និងស្រាវជ្រាវ សូមជម្រាបជូនដល់និស្សិតដែលកំពុងសរសេរសារណាបញ្ចប់ថ្នាក់ **បរិញ្ញាបត្រជំនាន់ទី ៨ ក្រុម១ (ជំនាន់ទី៦)** ទាំងអស់ឱ្យបានជ្រាបថា ដំណើរនៃកិច្ចសារណាត្រូវអនុវត្តតាមកម្មវិធីដូចខាងក្រោមៈ

**កាលបរិច្ឆេទប្រមូលសារណា និង Slide និងការឡើងការពារ**

- **ថ្ងៃ ច័ន្ទ ទី ១ ដល់ ២៥ ខែ ធ្នូ ឆ្នាំ ២០០៩** ផុតកំណត់ត្រឹម ម៉ោង **១៨:00 នាទី**
- ចំនួនសៀវភៅ **៥ ក្បាល** និង សៀវភៅ **Slide ៥ ក្បាល** ។

**កាលបរិច្ឆេទការពារ**

- ចាប់ផ្ដើមពី **ថ្ងៃ ច័ន្ទ ទី ១៨ ខែ មករា ឆ្នាំ ២០១០ ដល់ ២៦ ខែ កុម្ភៈ ឆ្នាំ ២០១០** ទៅតាមកាលវិភាគដែលបានកំណត់ ។

**រយៈពេលការឡើងការពារ**

- ប្រធានក្រុមឡើងធ្វើការណែនាំអំពីប្រធានបទ និងសមាជិកក្រុមព្រមទាំងធ្វើការឡើងចាប់ឆ្នោតម្នាក់មួយសន្លឹក (**១០ នាទី**)
- ការពារទៅតាមជំពូកដែលខ្លួនចាប់ឆ្នោតបាន (**ម្នាក់ ១០ នាទី**)
- សម្រាក (**៥ នាទី**)
- ប្រធានក្រុមបង្ហាញនូវអ្វីដែលខ្លួនធ្វើបានជាសង្ខេប (**១០ នាទី**)
- ចោទសួរពីគណកម្មការ (**ម្នាក់ ១០ នាទី**)

**លក្ខខណ្ឌនៃការឡើងការពារ**

- សារណាដែលអាចឡើងការពារបានលុះត្រាតែមានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមរចនាបថដែលបានកំណត់ និងមានការយល់ព្រមពីសាស្ត្រាចារ្យដឹកនាំ ។
- សមាជិកក្រុមម្នាក់ៗត្រូវឡើង Presentation ទាំងអស់គ្នា ។ បានន័យថាក្រុមនីមួយៗត្រូវរៀបចំ Slide និងពេលវេលាឱ្យបានត្រឹមត្រូវតាមសមាជិកក្រុមម្នាក់ៗ ហើយមានន័យគ្រប់គ្រាន់ទៅតាមជំពូកទាំងអស់ ។
- ការឡើងឧទ្ទេសនាមបង្ហាញគឺត្រូវធ្វើការចាប់ឆ្នោតមុននឹងឡើងការពារ ។
- ចំពោះក្រុមណាដែលអវត្តមានទៅតាមកាលវិភាគដែលបានកំណត់ ក្រុមនោះត្រូវលើកទៅការពារនៅជំនាន់ក្រោយ ហើយរាល់ការចំណាយផ្សេងៗទាំងអស់ត្រូវទទួលខុសត្រូវដោយខ្លួនឯង ។

*បញ្ជាក់* :

- និស្សិតទាំងអស់អាចការពារសារណារបស់ខ្លួនបានលុះត្រាតែលទ្ធផលនៃការប្រឡងទាំងអស់ជាប់ជាស្ថាពរ ។
- តំណាងក្រុមនីមួយត្រូវមកបំពេញទំរង់បែបបទសុំអនុញ្ញាតការពារសារណា និងខ្ចីសម្ភារៈពេលការពារ ។
- សម្លៀកបំពាក់ **បុរស** អាវស ពាក់ក្រវ៉ាត់ក ខោ ក្រម៉ៅ និងស្បែកជើងឃ្លុប ចំពោះ**នារី** សម្លៀកបំពាក់សមរម្យ ។